# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែកុម្ភៈ ឆ្នាំ២០១៥
## និងទិសដៅការងារ ខែមីនា ឆ្នាំ២០១៥

( ពីថ្ងៃទី២៦/០១/២០១៥ ដល់ ២៥/០២/២០១៥ )

ក្នុងគោលដៅចូលរួមចំណែកអនុវត្ត "គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល ក៏ដូចជាអនុវត្តតាមផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញកាលពី ខែមករា ឆ្នាំ ២០១៥ កន្លងទៅ សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

នៅក្នុងខែកុម្ភៈឆ្នាំ២០១៥នេះ មានការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានប្រតិបត្តិការដោយ មន្ទីរប្រឆាំងគ្រឿងញៀន និងបណ្តាស្នងការដ្ឋាននគរបាល ក៏ដូចជាបញ្ជាការដ្ឋានកងរាជអាវុធហត្ថ រាជធានី-ខេត្ត ចំនួន ២២ គឺ រាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, កណ្តាល, កំពង់ស្ពឺ, កំពង់ចាម, កំពង់ឆ្នាំង, សៀមរាប, កំពង់ធំ, បាត់ដំបង, បន្ទាយមានជ័យ, ស្ទឹងត្រែង, ព្រៃវែង, ក្រចេះ, ពោធិ៍សាត់, កំពត, កោះកុង, មណ្ឌលគិរី, ព្រះវិហារ, ឧត្តរមានជ័យ, រតនគិរី, កោះកុង និង ខេត្តត្បូងឃ្មុំ ។

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបដោយសមត្ថកិច្ចអនុវត្តន៍ច្បាប់ខាងលើ មានបទល្មើសគ្រឿងញៀនពាករណីធំៗ ដែលបង្ក្រាបដោយកម្លាំងរបស់មន្ទីរប្រឆាំងគ្រឿងញៀន សហការជាមួយស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ ១ ករណី, ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង ១ ករណី និងកងរាជអាវុធហត្ថរាជធានីភ្នំពេញ ១ ករណី ព្រមទាំងចាប់យកគ្រឿងញៀនសំយោគប្រភេទមេតំហ្វេតាមីនក្រាមម្សៅ ជិត ៣ គីឡូក្រាម ។

## II. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំលើការងារជាគោលសំខាន់ៗ មានជាអាទិ៍ ៖

- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវជំរុញលើការងាររៀបចំសាលារៀនបៃតង (សាលារៀនគ្មានគ្រឿងញៀន), ការ ប្រឡងប្រជែងតែងកំណាព្យដែលមានខ្លឹមសារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការផលិតឯកសារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន
- ក្រសួងសុខាភិបាល ត្រូវរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍នៅកម្ពុជា សម្រាប់ធ្វើជាមូលដ្ឋានបន្តការកៀរគរថវិកាជំនួយ ។ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវសហការជាមួយអង្គការ UNODC ដើម្បីធ្វើការបូកសរុបលទ្ធផលនៃការកៀរគរថវិកាជំនួយសម្រាប់អនុវត្តកម្មវិធីផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវបន្តជំរុញ ៖
    - ការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្ដោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (មណ្ឌលរបស់រដ្ឋ និង ឯកជន)
    - ការផលិតស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមណ្ឌលសុខភាព ដែលបានរៀបចំរួចក្នុងរាជធានីភ្នំពេញ និងជំរុញកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍នៅរាជធានីភ្នំពេញ ឱ្យបានឆាប់រហ័ស
    - ការរៀបចំខិត្តប័ណ្ណផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន និងខិត្តប័ណ្ណផ្សព្វផ្សាយពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
    - ការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយថែមទៀតពីកម្មវិធីម្ហូល/ស៊ីរ៉ាំង ការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមណ្ឌលសុខភាព-មន្ទីរពេទ្យបង្អែក និងការផ្តល់សេវាព្យាបាលរបស់អង្គការមិត្តសំឡាញ់
    - ការរៀបចំគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាអ្នកញៀន គ្រឿងញៀននៅក្នុងពន្ធនាគារ
    - ការរៀបចំកិច្ចប្រជុំជាមួយតំណាងអយ្យការនិងតុលាការ ពិសេសនៅរាជធានីភ្នំពេញពាក់ព័ន្ធនឹងការចោទប្រកាន់អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក
    - ការធ្វើសម្រង់ទិន្នន័យបទល្មើសនានាក្នុងឆ្នាំ២០១៤ ដែលកើតឡើងដោយសារការប្រើប្រាស់គ្រឿងញៀន និងបទល្មើសគ្រឿងញៀន ដោយបញ្ជាក់ពីមុខរបរជនល្មើសឱ្យបានច្បាស់លាស់
    - ការធ្វើសម្រង់ទិន្នន័យសំណុំរឿងបទល្មើសគ្រឿងញៀន ដែលនៅក្នុងដែនសមត្ថកិច្ចតុលាការ
    - ការរៀបចំព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
    - ការរៀបចំអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

នៅក្នុងខែកុម្ភៈឆ្នាំ២០១៥នេះ ផ្តើមចេញពីគោលការណ៍ដឹកនាំរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញា

ធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចជាអនុវត្តតាមផែនការសកម្មភាពនៃទិសដៅការងារ ដែលបានដាក់ចេញកាលពីខែមករាឆ្នាំ២០១៥ កន្លងទៅ ក្រសួង ស្ថាប័នជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត នៅតែបន្តអនុវត្តកម្មវិធីអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ តាមរយៈស្ថានីយវិទ្យុជាតិ វិទ្យុរាជធានី ខេត្ត តាមកម្មវិធីប្រចាំថ្ងៃ សប្តាហ៍ ខែ ដើម្បីលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

ដោយឡែក ការអប់រំពីបញ្ហាគ្រឿងញៀននៅតាមសហគមន៍ ក្រៅពីការចូលរួមដោយក្រសួង ស្ថាប័នជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក៏មានការចូលរួមអប់រំផ្សព្វផ្សាយនៅតាមសហគមន៍ ដោយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ៥ គឺ ខេត្តបាត់ដំបង, ស្វាយរៀង, កណ្តាល, កំពង់ឆ្នាំង និងខេត្តកំពង់ចាម ។ លទ្ធផលជារួម មានមហាជនចូលរួមប្រមាណ **១៩២.២១៨** នាក់ លើ **២១៣.១០៨** នាក់ នៃខែមករា ឆ្នាំ ២០១៥ (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី១) ។

ក្នុងចំណោមសកម្មភាពការងារខាងលើ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមអនុវត្តនូវការងារដូចខាងក្រោម ៖

- រៀបចំ និងអញ្ជើញក្រសួងសុខាភិបាល, ក្រសួងយុត្តិធម៌ និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីផ្សាយផ្ទាល់របស់ស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ តាមកម្មវិធី និងប្រធានបទ ដូចខាងក្រោម ៖
  - កម្មវិធីសុវត្ថិភាពអ្នក ក្រោមប្រធានបទ ការព្យាបាលអ្នកញៀនគ្រឿងញៀន (ដោយក្រសួងសុខាភិបាល)
  - កម្មវិធីចក្ខុវិស័យកម្ពុជា ក្រោមប្រធានបទ ការអនុវត្តច្បាប់ចំពោះអ្នកប្រើគ្រឿងញៀន (ដោយក្រសួងយុត្តិធម៌)
  - កម្មវិធីសភាអ៊ីនធឺណែត ក្រោមប្រធានបទ ការងារអប់រំបញ្ហាគ្រឿងញៀនក្នុងចំណោមសិស្សានុសិស្សទាំងក្នុង និងក្រៅប្រព័ន្ធអប់រំ (ដោយក្រសួងអប់រំ យុវជន និងកីឡា)
- រៀបចំកិច្ចប្រជុំជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិភាក្សាលើការរៀបចំសាលារៀនបៃតង (សាលារៀនគ្មានគ្រឿងញៀន), ការប្រឡងប្រជែងគូរគំនូរប្រឆាំងគ្រឿងញៀន និងការប្រឡងតែងកំណាព្យ កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៥
- សហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ មានអ្នកចូលរួមចំនួន **៤០០** នាក់
- រៀបចំខិត្តប័ណ្ណចំនួនពីរប្រភេទ សម្រាប់ផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងខិត្តប័ណ្ណសម្រាប់ផ្សព្វផ្សាយពីការផ្តល់សេវាព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក
- បន្តសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ ទូរទស្សន៍បាយ័ន, ទូរទស្សន៍ហង្សមាស, ម៉ាយធីវី បញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈកម្មវិធីប្រគំតន្ត្រីស្រុកស្រែ, កម្មវិធីតន្ត្រីទេសចរណ៍ខារ៉ាបាវ, តន្ត្រីកូកាកូឡា នៅខេត្តកំពង់ឆ្នាំង, ពោធិ៍សាត់, ត្បូងឃ្មុំ, កំពង់ធំ, កំពង់ស្ពឺ, កំពត និងខេត្តកណ្តាល មានមហាជនចូលរួមប្រមាណ ១៦៥.៤០០ នាក់ ។
- តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុង**ខែកុម្ភៈ ឆ្នាំ**

២០១៥ មានអ្នកអានចំនួន **២៨.៧៥២** ដង លើ **២៤.០៣៥** ដង នៃខែមករា ឆ្នាំ២០១៥ ។

## ២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់

- បានចូលរួមក្នុងកិច្ចប្រជុំ ស្តីពីការបង្ហាញនូវលទ្ធផលបឋមសម្រាប់ការសិក្សាស្រាវជ្រាវលើភាពខ្វះចន្លោះគោលនយោបាយទាក់ទងនឹងគ្រឿងញៀន នៃគម្រោងកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀននៅអាស៊ី ដែលរៀបចំដោយអង្គការ ខាន់ណា កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ (មន្រ្តីអគ្គលេខាធិការដ្ឋាន ០១ រូប)
- បានចាត់មន្ត្រីទៅចូលរួមកិច្ចប្រជុំ Asia-Pacific Intergovernmental Meeting on HIV and AIDs ពីថ្ងៃទី២៨-៣០ ខែមករា ឆ្នាំ២០១៥ នៅទីក្រុងបាងកក ប្រទេសថៃ (មន្រ្តីអគ្គលេខាធិការដ្ឋាន ០១ រូប) ។

### ២.២. ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

- រៀបចំកិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងកិច្ចដំណើរការការងារព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ (CBTx) នៅខេត្តបន្ទាយមានជ័យ (ថ្ងៃទី០៤/០២/២០១៥ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ មន្ត្រីអគ្គលេខាធិការដ្ឋាន ០៣ រូប)
- រៀបចំ និងសហការជាមួយក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចុះពិនិត្យនិងពិភាក្សាការងារពាក់ព័ន្ធនឹងកិច្ចដំណើរការរបស់មណ្ឌលសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (មណ្ឌលរបស់ឯកជន និងមណ្ឌលរបស់អង្គការ) ពីថ្ងៃទី ១០-១៣ ខែកុម្ភៈ ឆ្នាំ២០១៥ ចំនួន ៧ កន្លែងគឺ : មណ្ឌលអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈពន្លឺថ្មី, មណ្ឌលព្យាបាលជនប្រើប្រាស់គ្រឿងញៀន និងបណ្តុះបណ្តាលចំណេះដឹង, មណ្ឌលអង្គការ Assemble of god (ស្ត្រី), មណ្ឌលអង្គការ Assemble of god (បុរស), មណ្ឌលក្រោមការគ្រប់គ្រងរបស់អង្គការមិត្តសំឡាញ់, មណ្ឌលសង្គ្រោះជនរងគ្រោះដោយសារគ្រឿងញៀននៅកម្ពុជា និងមណ្ឌលសំចតម្លប់តាបាង (មន្រ្តីអគ្គលេខាធិការដ្ឋាន ០៣ រូប)
- រៀបចំកិច្ចប្រជុំដើម្បីពិភាក្សាអំពីការកែសម្រួលយន្តការគ្រប់គ្រង និងវិធីសាស្រ្តផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅតាមមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (២៤/០២/២០១៥ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ មន្ត្រីអគ្គលេខាធិការដ្ឋាន ០៤ រូប)
- សម្របសម្រួល និងសហការជាមួយក្រសួងសុខាភិបាល ដើម្បីរៀបចំបញ្ជីឈ្មោះនិងទីតាំងផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ជាមូលដ្ឋាន នៅទូទាំងប្រទេសសរុបចំនួន ២៤០ កន្លែង ក្នុងនោះមាន ៦០ មន្ទីរពេទ្យថ្នាក់ជាតិ និងមន្ទីរពេទ្យបង្អែក និង ១៨០ មណ្ឌលសុខភាព ដែលអាចទទួលព្យាបាលអ្នកជំងឺផ្លូវចិត្ត និងអ្នកញៀនគ្រឿងញៀន តាមរយៈការផ្តល់សេវាពិគ្រោះជំងឺ ការផ្តល់ប្រឹក្សា និងការសម្រាកពេទ្យ ដូចមានបញ្ជីឈ្មោះកន្លែងផ្តល់សេវាក្នុងតារាងឧបសម្ព័ន្ធទី៣

- សម្របសម្រួលនិងសហការជាមួយក្រសួងសុខភិបាល ដើម្បីរៀបចំរបាយការណ៍ស្តីពី លទ្ធផលនៃការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ជាមូលដ្ឋាននៅកម្ពុជា
- សម្របសម្រួលជូនក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីចាត់បញ្ជូនមន្ត្រីទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពី កម្មវិធីមូលដ្ឋានក្នុងការព្យាបាលអ្នកញៀនគ្រឿងញៀន ដែលបានរៀបចំនៅប្រទេសថៃ ចាប់ពីថ្ងៃទី០៩ ខែកុម្ភៈ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

- ចូលរួមប្រជុំពិភាក្សាលើករណីបទល្មើស ធក់ ចោរកម្ម និង ប្រើប្រាស់គ្រឿងញៀន នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៥ (អគ្គលេខាធិការចូលរួម)
- រៀបចំ និងចូលរួមកិច្ចប្រជុំគណៈកម្មការពិគ្រោះយោបល់គម្រោង លើកទី៧ (ហៅកាត់ថា C-PAC) នៃគម្រោងស្តីពី ភាពជាដៃគូនៃមន្ត្រីអនុវត្តន៍ច្បាប់ក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន (ហៅកាត់ថា Patrol) ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០១៥ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ (មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ០៦ រូប មន្ត្រីក្រសួងពាក់ព័ន្ធ ០៩ រូប)
- រៀបចំពិធីប្រគល់រថយន្តសម្រាប់ការបណ្តុះបណ្តាលចល័តស្តីពីការត្រួតពិនិត្យគ្រឿងញៀន (E-Learning) និងបរិក្ខាររបស់គម្រោង PATROL កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥
- ចូលរួមសិក្ខាសាលាមហាអនុតំបន់ទន្លេមេគង្គ ឆ្នាំ២០១៥ ស្តីពីកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនឆ្លងដែន កាលពីថ្ងៃទី២០-២១ ខែមករា ឆ្នាំ២០១៥ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០២ រូប)
- ចូលរួមសិក្ខាសាលាមហាអនុតំបន់ទន្លេមេគង្គ ឆ្នាំ២០១៥ ដើម្បីបង្កើតបទដ្ឋានសម្រាប់ការអនុវត្តការងារទាក់ទងទៅនឹងការបញ្ជូន និងការវិភាគសំណាកគ្រឿងញៀន ពីថ្ងៃទី២៧-២៨ ខែមករា ឆ្នាំ២០១៥ នៅ ទីក្រុងប៉េកាំង ប្រទេសចិន (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ នាក់) ។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

- បទល្មើសគ្រឿងញៀន សរុបរួម **១៨៤ ករណី** លើ ២៣៨ ករណី នៃខែមករា ឆ្នាំ២០១៥
- ជនសង្ស័យឃាត់ខ្លួន សរុបរួម **៤២២ នាក់** (ស្រី ៧២ នាក់) លើ ៤៧៩ នាក់ នៃខែមករា ឆ្នាំ ២០១៥

ក្នុងចំនួនបទល្មើសគ្រឿងញៀន **១៨៤ ករណី** និងជនសង្ស័យទាំង **៤២២ នាក់** ខាងលើគឺ :

- បទល្មើសគ្រឿងញៀន បង្ក្រាបដោយសមត្ថកិច្ចនគរបាលជាតិ **១៤៨ ករណី**, ជនសង្ស័យ **៣១៣ នាក់** (ស្រី ៤៧ នាក់)
- បទល្មើសគ្រឿងញៀន បង្ក្រាបដោយសមត្ថកិច្ចកងរាជអាវុធហត្ថ **៣៦ ករណី**, ជនសង្ស័យ **១០៩ នាក់** (ស្រី ២៥ នាក់)

ក្នុងចំនួនជនសង្ស័យ ដែលបានឃាត់ខ្លួនទាំង ៤២២ នាក់ ខាងលើ មាន ០៣ សញ្ជាតិ គឺ ខ្មែរ ៤១៤ នាក់ (ស្រី ៧២ នាក់), វៀតណាម ៧ នាក់ (ប្រុស), អង់គ្លេស ០១ (ប្រុស) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ។

- **វត្ថុតាងគ្រឿងញៀនចាប់យក** មេតំហ្វេតាមីន WY ៣៤,១៣ ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ ICE ៣.៣៤៥,៥៨ ក្រាម, ហេរ៉ូអ៊ីន ២,១១ ក្រាម, កេតាមីន ០,៥០, កញ្ឆាក្រៀម ១៨.៦២ ក្រាម និង ម្សៅសង្ស័យគ្រឿងញៀន ១៤១,២៥ ក្រាម
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន** ដែលបានចាប់យករួមមាន ម៉ូតូ ៦៨ គ្រឿង, រថយន្ត ៦ គ្រឿង, ប្រាក់កម្ពុជា ១៤.៣០៧.៨០០ រៀល, ប្រាក់វៀតណាម ៤៦៧.០០០ ដុង, ប្រាក់ថៃ ៧.០០០ បាត, ប្រាក់អាមេរិក ៦៦២ ដុល្លារ (**ដូចមានក្នុងតារាង ឧបសម្ព័ន្ធទី២**)
- ជនសង្ស័យចាប់តាមដីកា មាន ១៧ ដីកា = មនុស្ស ១៦ នាក់ (ស្រី ២ នាក់) ជនជាតិខ្មែរ
- ការធ្វើកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ក្នុងខែកុម្ភៈ ឆ្នាំ២០១៥ សរុបចំនួន ១៥០ សំណាក = ១២៧ ករណី ក្នុងនោះ ៖
  - **សំណាកវិជ្ជមានសារជាតុញៀន មាន ១៤២ សំណាក ៖**

    -មេតំហ្វេតាមីន ICE ១១៦ សំណាក = ៧៧,៣៣ %

    -មេតំហ្វេតាមីន WY ១៣ សំណាក = ៨,៦៦ % -កេតាមីន ០៦ សំណាក = ៤,០០ %

    -ហេរ៉ូអ៊ីន ០១ សំណាក = ០,៦៦ % -កញ្ឆា ០២ សំណាក = ១,៣២ %

    -MDMA ០១ សំណាក = ០,៦៦ % -ផ្សឹដូ-អេហ្វេឌ្រីន០៣ សំណាក = ២,០០ %
  - **សំណាកអវិជ្ជមានសារជាតុញៀន ០៨ សំណាក**

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារជាតុគីមីផ្សំ, វត្ថុធាតុដើម ដែលមានច្បាប់អនុញ្ញាតឲ្យនាំចូលនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៥ នេះ មានដូចតទៅ ៖
  - វត្ថុធាតុដើមចម្រុះ ដែលពាក់ព័ន្ធនឹងតារាងទី**IV** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន សរុបចំនួន **១០០.៨៥០** គ.ក្រ ក្នុងនោះ ៖
    - ✓ វត្ថុធាតុដើមដែលចេញ បទដ្ឋានបច្ចេកទេស ដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម មាន ៨.០០០ គ.ក្រ
    - ✓ វត្ថុធាតុដើម ដែលចេញអាជ្ញាបណ្ណដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាន ៩២.៨៥០ គ.ក្រ (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៣)
- បាននិងកំពុងបន្តកិច្ចសហការជាមួយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពាក់ព័ន្ធនឹងនីតិវិធីក្នុងការប្រគល់ជូនក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដើម្បីគ្រប់គ្រងបន្តនិងចាត់ចែងតាមសមត្ថកិច្ចនូវសារជាតុគីមី ចំនួន ១៤ មុខ ទម្ងន់ ១៨ តោន ៩០០ គីឡូក្រាម
- បាននិងកំពុងបន្តកិច្ចសហការជាមួយអង្គការ UNODC ដើម្បីរៀបចំបញ្ជូនសំណាកម្សៅល្លិរមៀតទៅធ្វើការវិភាគឱ្យបានច្បាស់លាស់ថានៅក្នុងម្សៅនោះ មានផ្ទុកនូវសារជាតុអ្វីខ្លះ
- បាននិងកំពុងបន្តការរៀបចំឯកសាររបាយការណ៍សំយោគពាក់ព័ន្ធការចរាចរ ការរឹបអូសប្រេងម្រះព្រៅភ្នំ កន្លងមក

- ក្រសួងសុខាភិបាល បានចេញលិខិត លេខ ០៨៦៨ អបស.ឱអបស ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៤ ដើម្បីហាមឃាត់ការនាំចូលនូវសារជាតុ Pseudo Ephedrine និង Ephedrine ដូចតទៅ ៖
  - បញ្ឈប់ការនាំចូលឱសថ និងបញ្ឈប់ការសុំចុះបញ្ជិកាឱសថ ដែលមានរូបមន្តលាយផ្សំដោយសារជាតុ Pseudo Ephedrine និង Ephedrine
  - បញ្ឈប់ការនាំចូលវត្ថុធាតុដើម Pseudo Ephedrine និង Ephedrine សម្រាប់យកមកផលិតឱសថក្នុងស្រុក ចំពោះឱសថដែលមានសារជាតុ Ephedrine សម្រាប់ចាក់ (Injection) ដែលនាំចូលបានក្នុងបរិមាណសមស្របណាមួយសម្រាប់ប្រើប្រាស់ក្នុងមន្ទីរពេទ្យរដ្ឋតែប៉ុណ្ណោះ
  - ចំពោះលិខិតអនុញ្ញាតនាំចូលសារជាតុ Pseudo Ephedrine និង Ephedrine ដែលបានអនុញ្ញាតរួចហើយ អាចផលិត និងចែកចាយរហូតអស់ស្តុកពីឃ្លាំង ។ សហគ្រាសផលិតឱសថទាំងអស់ត្រូវធ្វើរបាយការណ៍បញ្ជាក់នូវចំនួនស្តុក ដែលនៅសល់នៃសារជាតុ Pseudo Ephedrine និង Ephedrine ព្រមទាំងផលិតផលសម្រេចមកក្រសួងសុខាភិបាល
- បានចូលរួមសិក្ខាសាលាវេទិកាតំបន់អាស៊ានស្តីពីសារជាតុគីមីផ្សំ និងគ្រឿងញៀនសំយោគ ដែលបានរៀបចំនៅទីក្រុងបាងកក ប្រទេសថៃ (ថ្ងៃទី៨-១៤/០២/២០១៥) ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

- បាននិងកំពុងបន្តយកចិត្តទុកដាក់ជំរុញការរៀបចំកិច្ចប្រជុំទ្វេភាគីថ្នាក់ខេត្ត ដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសវៀតណាម ឡាវ ថៃ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនឱ្យបានទៀងទាត់
- សម្របសម្រួលជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ ដើម្បី ៖
  - ✓ ចាត់បញ្ជូនមន្ត្រីរបស់ក្រសួងពាក់ព័ន្ធ ទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីកម្មវិធីមូលដ្ឋានក្នុងការព្យាបាលអ្នកញៀនគ្រឿងញៀន នៅប្រទេសថៃ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥
  - ✓ បាននិងកំពុងបន្តកិច្ចសហការ និងសម្របសម្រួលជាមួយភាគីថៃ (ONCB) ដើម្បីរៀបចំពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការលើការងារអនុវត្តន៍ច្បាប់ និងការត្រួតពិនិត្យគ្រឿងញៀន
- បានសម្របសម្រួលដំណើរទស្សនកិច្ច ជូនគណៈប្រតិភូជាន់ខ្ពស់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អញ្ជើញទៅកាន់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

- បានសម្របសម្រួលជូនមន្ត្រីជំនាញរបស់ក្រសួងពាក់ព័ន្ធ ដើម្បីទៅចូលរួមក្នុងកិច្ចប្រជុំ Joint Force ស្តីពីកិច្ចប្រតិបត្តិការប្រឆាំងឧក្រិដ្ឋកម្មគ្រឿងញៀនឆ្លងដែន និងកិច្ចប្រជុំក្រុមការងារស្តីពីការត្រួតពិនិត្យស៊ើបអង្កេតរួមនៅតាមកំពង់ផែ ការស៊ើបអង្កេតតាមគោលដៅបទល្មើស និងការត្រួតពិនិត្យសារជាតុប្រភេទថ្មី ពីថ្ងៃទី០២-០៤ ខែកុម្ភៈ ឆ្នាំ២០១៥ នៅប្រទេសចិន (មន្ត្រីស្ថាប័នពាក់ព័ន្ធ ០៣ រូប)
- បានចូលរួមក្នុងកិច្ចប្រជុំវាយតម្លៃ ស្តីពីការអនុវត្តគោលការណ៍អាស៊ានគ្មានគ្រឿងញៀនឆ្នាំ២០១៥ កាល

ពីថ្ងៃទី ០៥-០៦ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីក្រុងបាងកក ប្រទេសថៃ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០២ រូប)

- បានសម្របសម្រួលជាមួយរដ្ឋាភិបាលជប៉ុន ដើម្បីទៅចូលរួមសន្និសីទអន្តរជាតិ ស្តីពីការអនុវត្តច្បាប់គ្រឿងញៀន នៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក កាលពីថ្ងៃទី២៤-២៦ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប)
- បានសម្របសម្រួលជាមួយអង្គការ UNODC ដើម្បីរៀបចំ និងចូលរួមកិច្ចប្រជុំគណៈកម្មការពិគ្រោះយោបល់គម្រោង លើកទី៧ (ហៅកាត់ថា C-PAC) នៃគម្រោងស្តីពីភាពជាដៃគូនៃមន្ត្រីអនុវត្តន៍ច្បាប់ក្នុងតំបន់(ហៅកាត់ថា Patrol) ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០១៥ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០៦ រូប / មន្ត្រីសរុប ១៥ រូប)
- បានសម្របសម្រួលជាមួយអង្គការ UNODC ដើម្បីរៀបចំពិធីប្រគល់រថយន្តសម្រាប់ការបណ្តុះបណ្តាលចល័តស្តីពីការត្រួតពិនិត្យគ្រឿងញៀន (E-Learning) និងបរិក្ខាររបស់គម្រោង PATROL កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បាននិងកំពុងបន្តការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បាននិងកំពុងបន្តការពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បាននិងកំពុងបន្តការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល ការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន
- បាននិងកំពុងបន្តការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន ។

# IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែមីនា ឆ្នាំ២០១៥

## ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

- ចូលរួមសន្និសីទសារព័ត៌មានមហោស្រពតន្ត្រី និងចម្រៀងសម័យថ្នាក់ជាតិ ឆ្នាំ២០១៥ នាថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ នៅក្រសួងព័ត៌មាន ។
- រៀបចំ សម្របសម្រួល និងអញ្ជើញវាគ្មិនជាតំណាងមកពីក្រសួងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងទេចរណ៍ និងអតីតអ្នកញៀនគ្រឿងញៀន ដើម្បីផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីសភា អ៊ីនធឺណែតនៃស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥
- ចូលរួមសិក្ខាសាលាស្តីពីការបញ្ជ្រាបវិធានការ និងហានិភ័យនៃការសេពគ្រឿងញៀន ដល់អ្នកសារព័ត៌មានមកពីខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ និងខេត្តកោះកុង ដែលរៀបចំដោយក្រសួងព័ត៌មាន នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ នៅខេត្តព្រះសីហនុ
- បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យ ឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន

- ត្រៀមចូលរួមសហការជាដៃគូជាមួយក្រសួងព័ត៌មាន ក្នុងការរៀបចំមហោស្រពប្រឡងតន្ត្រីនិងចម្រៀងសម័យថ្នាក់ជាតិ ឆ្នាំ២០១៥
- បន្តជំរុញក្រសួងអប់រំ យុវជន និងកីឡា លើការងាររៀបចំសាលារៀនបៃតង (សាលារៀនគ្មានគ្រឿងញៀន), ការងារប្រឡងប្រជែងតែងកំណាព្យដែលមានខ្លឹមសារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការផលិត ឯកសារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន
- សហការជាមួយក្រសួងទេសចរណ៍ ដើម្បីរៀបចំផលិតបន្ថែមនូវស្ទីកឃ័រ (Sticker) ផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន អេដស៍ ការប្រើប្រាស់អាវុធ និងការជួញដូរមនុស្ស
- បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ និងវិស័យឯកជន ដើម្បីជំរុញការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមប្រព័ន្ធផ្សព្វផ្សាយនានា
- បន្តជំរុញការងារបណ្តុះបណ្តាលក្រុមជនបង្គោលអប់រំពីបញ្ហាគ្រឿងញៀននៅតាមក្រសួង-ស្ថាប័ន រោងចក្រ សហគ្រាស និង នៅតាមសហគមន៍
- សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តគោលដៅ និងវិស័យឯកជន ដើម្បីបន្តការបញ្ជ្រាបការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនឯកជន

## ២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

- ជំរុញសកម្មភាពចែកចាយឯកសារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ឱ្យកាន់តែសកម្មថែមទៀតនៅតំបន់គោលដៅសំខាន់ៗ ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀនអាចទៅទទួលយកសេវាព្យាបាល នៅមន្ទីរពេទ្យបង្អែក ឬ មណ្ឌលសុខភាព ដែលនៅជិត
- ជំរុញក្រសួងសុខាភិបាល រៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍នៅកម្ពុជា សម្រាប់ធ្វើជាមូលដ្ឋានបន្តការកៀរគរថវិកាជំនួយ
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយអង្គការ UNODC ដើម្បីធ្វើការបូកសរុបលទ្ធផល នៃការកៀរគរថវិកាជំនួយសម្រាប់អនុវត្តកម្មវិធីព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- បន្តជំរុញក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ក្នុងការពង្រឹងយន្តការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- បន្តការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បន្តការផលិតស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមណ្ឌលសុខភាព ដែលបានរៀបចំរួចក្នុងរាជធានីភ្នំពេញ និងជំរុញការផលិតខិត្តប័ណ្ណផ្សព្វផ្សាយពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍

- បន្តកិច្ចសហការជាមួយក្រសួងសុខាភិបាល គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយថែមទៀត ពីកម្មវិធីម្ជុល/ស៊ីរ៉ាំង និងការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងសេវាព្យាបាលរបស់អង្គការមិត្តសំឡាញ់
- រៀបចំកិច្ចប្រជុំជាមួយតំណាងអយ្យការនិងតុលាការ ពិសេសនៅរាជធានីភ្នំពេញ ពាក់ព័ន្ធនឹងការចោទប្រកាន់អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាលនៅតាម មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក
- ចូលរួមប្រជុំជាមួយសាលារាជធានីភ្នំពេញ ដើម្បីធ្វើការត្រួតពិនិត្យលទ្ធផលការងារដែលបានអនុវត្តកន្លងមក និងរកវិធានការបន្តពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

- បន្តចូលរួមសហការជាមួយក្រសួងការពារជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់កងយោធពលខេមរភូមិន្ទនៅតាមតំបន់ប្រតិបត្តិការសឹករងចំនួន ១២ និងសាលានាយទាហានចំនួន ៣
- ត្រៀមរៀបចំបង្កើតក្រុមការងារទប់ស្កាត់ការចរាចរគ្រឿងញៀនឆ្លងកាត់ច្រកអាកាសយានដ្ឋានអន្តរជាតិ
- សហការ និងជំរុញមន្ទីរប្រឆាំងគ្រឿងញៀននៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាល បំប៉នជំនាញស្តីពីការស្រាវជ្រាវ ស៊ើបអង្កេត និងការកសាងឯកសារសំណុំរឿង នីតិវិធីក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន ដល់មន្ត្រីនគរបាល ដែលមានភារកិច្ចពាក់ព័ន្ធ នៅតាមបណ្តាខេត្ត គោលដៅ
- សហការជាមួយស្ថាប័នអនុវត្តន៍ច្បាប់ ធ្វើសម្រង់ទិន្នន័យបទល្មើសនានាក្នុងឆ្នាំ២០១៤ ដែលកើតឡើងដោយសារការប្រើប្រាស់គ្រឿងញៀន និងបទល្មើសគ្រឿងញៀន ដោយបញ្ជាក់ពីមុខរបរជនល្មើសឱ្យបានច្បាស់លាស់
- បន្តជំរុញការធ្វើសម្រង់ទិន្នន័យសំណុំរឿងបទល្មើសគ្រឿងញៀន ជាមួយក្រសួងយុត្តិធម៌
- បន្តរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមប្រព័ន្ធកុំព្យូទ័រ(CBT) នៅនឹងកន្លែង (នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣)
- ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែនតាមប្រព័ន្ធអេឡិច-ត្រូនិច (E-Learning)
- ចុះពង្រឹងតាមដានការអនុវត្តច្បាប់ និងការអនុវត្តសាលក្រមតុលាការ របស់មន្ត្រីអនុវត្តន៍ច្បាប់នៅតាម រាជធានីខេត្តគោលដៅ
- ត្រៀមរៀបចំពិធីប្រកាសសមាសភាព តួនាទី ភារកិច្ចរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅទូទាំងប្រទេស ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

- រៀបចំឯកសារសម្រាប់បណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការស៊ើបអង្កេតការចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់
- បន្តជំរុញក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម
- សិក្សាស្រាវជ្រាវប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃ

ប្រសាទ ដើម្បីដាក់បញ្ចូលទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- រៀបចំឯកសាររបាយការណ៍សំយោគពាក់ព័ន្ធនឹងការចរាចរ ការរឹបអូសប្រេងម្រះព្រៅភ្នំ កន្លងមក ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

- សម្របសម្រួលជាមួយប្រទេសថៃ ឡាវ វៀតណាម ក្នុងការជំរុញកិច្ចប្រជុំឲ្យបានទៀងទាត់ រវាងថ្នាក់ខេត្ត និងខេត្ត ស្រុកនិងស្រុកជាប់ព្រំដែនកម្ពុជា-ថៃ / កម្ពុជា-ឡាវ / កម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដោយមានការចូលរួមពីផ្នែកកងទ័ព
- ពង្រឹងយន្តការនៃកិច្ចសហប្រតិបត្តិការទ្វេភាគី របស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា- ថៃ / កម្ពុជា-ឡាវ និង កម្ពុជា-វៀតណាម
- បន្តកិច្ចសហការ និងសម្របសម្រួលជាមួយការិយាល័យត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដើម្បីរៀបចំពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការលើការងារអនុវត្តន៍ច្បាប់ និងការត្រួតពិនិត្យគ្រឿងញៀន
- សម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដើម្បីចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់ ចំនួន ២៣ រូប ទៅចូលរួមសិក្ខាសាលា ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-ថៃ នៅទីក្រុងបាតាយ៉ា ប្រទេសថៃ ថ្ងៃទី២៥-២៧/៣/២០១៥ ។
- សម្របសម្រួលជាមួយគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀន ប្រទេសវៀតណាម និងប្រទេសឡាវ ដើម្បីរៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.៣ ទៅកាន់ប្រទេសវៀតណាមនិងឡាវ ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

- សហការជាមួយអង្គការ UNODC ចុះត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគម្រោង PATROL ដោយការិយា-ល័យ BLO កម្ពុជា
- សម្របសម្រួលជាមួយអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ស្តីពីការពង្រឹងការអនុវត្តរបស់ការិយល័យ BLOកម្ពុជា
- បង្កើនកិច្ចសហការជាមួយអង្គការ UNODC ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនតាមយន្តការនៃបណ្តាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ
- សម្របសម្រួលរៀបចំដំណើរទស្សនកិច្ចផ្លូវការជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.៣ អញ្ជើញទៅសាធារណរដ្ឋប្រជាមានិតចិន ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាអ្នកច្បាប់របស់រាជរដ្ឋាភិបាល ដើម្បីពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥)
- ត្រៀមរៀបចំកិច្ចប្រជុំត្រួតពិនិត្យ ឯកសារពាក់ព័ន្ធនឹងសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន និងកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- រៀបចំផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- ត្រៀមរៀបចំកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៤ និងទិសដៅការងារ ឆ្នាំ ២០១៥
- បន្តការកែសម្រួលសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល ការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយនិងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន
- បន្តការកែសម្រួលសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បន្តជំរុញការរៀបចំយន្តការគណៈកម្មការអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀន ពីថ្នាក់រាជធានីរហូតដល់ខណ្ឌ សង្កាត់ដើម្បីចូលរួមចំណែកក្នុងការគាំទ្រកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ដោយធ្វើសកម្មភាពនៅតំបន់គោលដៅសំខាន់ៗ
- ជំរុញការរៀបចំគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាគ្រឿងញៀននៅក្នុងពន្ធនាគារ
- រៀបចំកម្មវិធីផ្សព្វផ្សាយអំពី អនុសញ្ញាអន្តរជាតិស្តីពីគ្រឿងញៀន ដល់មន្ត្រីរាជការនៅតាមក្រសួង ស្ថាប័ន ដែលជាសមាជិករបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- រៀបចំកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដល់ មេឃុំ ចៅសង្កាត់ នគរបាលប៉ុស្តិ៍ រដ្ឋបាល មន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធ នៅតាមរាជធានី ខេត្ត ។

**អគ្គលេខាធិការ**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.៣
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣

"ដើម្បីជូនជ្រាប"

- ក្រសួង សមាជិក អ.ជ.ប.គ.៣
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

- ឯកសារ